

# ធានារ៉ាប់រងបន្ទាប់ពីមានផ្ទៃពោះ (APC)

ធានារ៉ាប់រងបន្ទាប់ពីមានផ្ទៃពោះ (APC) របស់ Apple Health (Medicaid) ផ្ដល់ជូនសេវាកម្មដើម្បីគាំទ្រដល់សុខុមាលភាពផ្លូវចិត្ត ផ្លូវកាយ និងផ្លូវអារម្មណ៍របស់អ្នក សម្រាប់រយៈពេល 12 ខែបន្ទាប់ពីមានផ្ទៃពោះ។

## អត្ថប្រយោជន៍ និងសេវាកម្ម

APC ផ្ដល់ជូនការថែទាំតាមដានក្រោយសម្រាល និងផ្ដល់សេវាថែទាំសុខភាពបន្ថែមដោយឥតគិតថ្លៃពីអ្នក។ អត្ថប្រយោជន៍រួមមានការថែទាំមាត់ធ្មេញ សុខភាពអាកប្បកិរិយា និងសេវាកម្មផ្សេងទៀតដែលបានធានារ៉ាប់រងដោយ Apple Health។ ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ការធានាមានរយៈពេលរហូតដល់ 12 ខែបន្ទាប់ពីការមានផ្ទៃពោះរបស់អ្នកបញ្ចប់ដោយមិនគិតពីការប្រែប្រួលប្រាក់ចំណូលឡើយ។

ចូលមើល **hca.wa.gov/apple-health-services** ដើម្បីស្វែងយល់ថាសេវាកម្មអ្វីខ្លះត្រូវបានធានារ៉ាប់រងក្រោម Apple Health។

## តើខ្ញុំមានសិទ្ធិទទួលបានឬទេ?

ដើម្បីមានសិទ្ធិទទួលបានកម្មវិធី **APC** អ្នកត្រូវតែ៖

- ធ្លាប់មានផ្ទៃពោះក្នុងរយៈពេល 12 ខែចុងក្រោយ។
- រស់នៅក្នុងរដ្ឋវ៉ាស៊ីនតោន។
- មានប្រាក់ចំណូលប្រចាំខែដែលបំពេញតាមស្ដង់ដារដែលបានរាយនៅខាងក្រោយ។
- មិនមានសិទ្ធិទទួលបានកម្មវិធី Apple Health ផ្សេងនោះទេ។

ស្ថានភាពអន្តោប្រវេសន៍មិនប៉ះពាល់ដល់សិទ្ធិទទួលបានទេ។ ស្វែងយល់បន្ថែមនៅ hca.wa.gov/apc។

Washington Apple Health

Washington State Health Care Authority

## តើចំនួនច្រើនបំផុតប៉ុណ្ណាដែលខ្ញុំអាចរកបានក្នុងមួយខែដើម្បីមានលក្ខណ:សម្បត្តិគ្រប់គ្រាន់?

| បុគ្គលទោល | គ្រួសារដែលមានសមាជិក **2** នាក់ | គ្រួសារដែលមានសមាជិក **3** នាក់ |
|---|---|---|
| ប្រច **$2,485** | ប្រច **$3,373** | ប្រ **$4,260** |
| គ្រួសារដែលមានសមាជិក **4** នាក់ | គ្រួសារដែលមានសមាជិក **5** នាក់ | គ្រួសារដែលមានសមាជិក **6** នាក់ |
| ប្រ **$5,148** | ប្រ **$6,036** | ឱប្រ **$6,923** |

## តើអ្នកកំពុងមានផ្ទៃពោះ ហើយមានធានារ៉ាប់រង Apple Health រួចហើយ?

ប្រសិនបើអ្នកមានធានារ៉ាប់រង Apple Health រួចហើយ អ្នកនឹងត្រូវបញ្ជូនទៅ APC នៅពេលអ្នកធ្វើបច្ចុប្បន្នភាពស្ថានភាពមានផ្ទៃពោះរបស់អ្នក។

- ប្រសិនបើអ្នកមានធានារ៉ាប់រងតាមរយ: Washington Healthplanfinder សូមធ្វើការផ្លាស់ប្តូរនៅ **wahealthplanfinder.org**។
- ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងដោយ Apple Health Classic Medicaid (អាយុ 65 ឆ្នាំ ឬលើសនេះ, ពិការភ្នែក ឬមានពិការភាព) សូមធ្វើការផ្លាស់ប្តូរនៅ **washingtonconnection.org**។

## តើអ្នកធ្លាប់មានផ្ទៃពោះក្នុងពេល 12 ខែចុងក្រោយ ហើយមិនមានធានារ៉ាប់រង Apple Health មែនទេ?

**អ្នកអាចមានសិទ្ធិទទួលបាន APC។ សូមដាក់ពាក្យសុំឥឡូវនេះ។**

- តាមអ៊ីនធឺណិត៖ ចូលទៅ **wahealthplanfinder.org** - ជ្រើសរើសប៊ូតុង “ដាក់ពាក្យសុំឥឡូវនេះ”។
- កម្មវិធីទូរសព្ទចល័ត៖ ទាញយកកម្មវិធី WAPlanfinder។
- ទូរសព្ទ៖ ហៅទូរសព្ទទៅ Washington Healthplanfinder តាមលេខ 1-855-923-4633។
- ក្រដាស៖ ទាញយកពាក្យសុំនៅ **hca.wa.gov/health-care-application**។
- ដោយផ្ទាល់៖ ធនធានក្នុងតំបន់ដែលឥតគិតថ្លៃបន្ថែម អាចជួយអ្នកដាក់ពាក្យសុំធានារ៉ាប់រងសុខភាព។
    - **wahealthplanfinder.org** - ស្វែងរកឧបករណ៍រុករកតាមរយ:តំណគាំទ្រអតិថិជន។



ប្រសិនបើអ្នកត្រូវការការសម្របសម្រួល ឬទាមទារឯកសារក្នុងទម្រង់ ឬភាសាមួយផ្សេង សូមទូរសព្ទទៅលេខ 1-800-562-3022 (TRS: 711)